## ស្ថានទូតអូស្ត្រាលីភ្នំពេញ

<u>សេចក្តីប្រកាសព័ត៌មាន</u>

# ប្រទេសអូស្ត្រាលីនិងកម្ពុជា បង្កើតកិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រី

កាលពីថ្ងៃម្សិលមិញ រដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាដើម្បីបង្កើតកិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រី។

អូស្ត្រាលី និងកម្ពុជាមានទំនាក់ទំនងទ្វេភាគីយូរអង្វែងរយៈពេល 65 ឆ្នាំមកហើយ។

លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **អេនជេលឡា ខកខឺរ៉េន** បានមានប្រសាសន៍ថា "ទំនាក់ទំនងទ្វេភាគីរបស់យើងត្រូវបានពង្រឹងតាមរយៈការប្តេជ្ញាចិត្តរួមគ្នាដើម្បីធ្វើឱ្យតំបន់របស់យើងកាន់តែរឹងមាំ ការស្វែងរកឱកាសសហការគ្នា និងការបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋកម្ពុជានិងអូស្ត្រាលី"។

កិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រីនេះ នឹងផ្តល់នូវយន្តការដែលយើងអាចពង្រឹងការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យទាំងអស់។

លោកជំទាវបានបន្តទៀតថា "យើងរំពឹងថានឹងមានការផ្លាស់ប្តូរយោបល់អំពីកិច្ចសហប្រតិបត្តិការទ្វេភាគី មានជាអាទ៍កម្មវិធីអភិវឌ្ឍរបស់អូស្ត្រាលីនៅកម្ពុជា ទំនាក់ទំនងផ្នែកកិច្ចការអប់រំទៅវិញទៅមក កម្មវិធីកិច្ចសហប្រតិបត្តិការការពារជាតិ ព្រមទាំងការពង្រឹងការអនុវត្តច្បាប់ និងសន្តិសុខ"។

លោកជំទាវបានបន្ថែមថា "យើងក៏នឹងប្រើប្រាស់កិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រីនេះដើម្បីពិភាក្សាពីបញ្ហាប្រឈមនានាថ្នាក់តំបន់ រួមមានការប្រឆាំងនឹងបទល្មើសឆ្លងដែន ការធ្វើចំណាកស្រុកមិនប្រក្រតី និងបញ្ហាសិទ្ធិមនុស្សជាដើម"។

កិច្ចពិគ្រោះឧត្តមមន្ត្រីលើកទីមួយ នឹងធ្វើឡើងនៅក្នុងប្រទេសកម្ពុជានាប៉ុន្មានខែខាងមុខ។

**ទំនាក់ទំនងព័ត៌មាន** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧**